# ព្រះរាជក្រឹត្យ

នស/រកត/០៨០១/២៦៤

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧបគោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៩៩៩/០៣ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការហាមប្រាម ការប្រើប្រាស់គ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦៩៩/១៣៨ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីវិសោធនកម្មលើព្រះរាជក្រឹត្យ ស្តីពីការបង្កើតមជ្ឈមណ្ឌលសកម្មភាពកំចាត់កម្ពុជា
- បានទ្រង់យល់ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៧ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពី ការតែងតាំងក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលស្នើសុំរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ។

# ក្រោសបន្ទាប់

## ជំពូកទី ១
## នីតិសារជាតិនៃមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា

**មាត្រា ១ :**

ត្រូវបានបង្កើតមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ហៅកាត់ថា ម.ស.ម.ក. ។ ម.ស.ម.ក. ជាគ្រឹះស្ថានសាធារណៈរដ្ឋបាលមានលក្ខណៈជានីតិបុគ្គល ដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ។

ម.ស.ម.ក មានសិទ្ធិដើម្បី :

ក. ចុះកិច្ចសន្យា ឬបំពេញកាតព្វកិច្ចផ្សេងទៀត ដើម្បីអោយសំរេចបេសកកម្មរបស់ខ្លួន ។

ខ. ជ្រើសរើស និងប្រើប្រាស់បុគ្គលិកទាំងឡាយ ដែលចាំបាច់សំរាប់សកម្មភាពរបស់ខ្លួន ។

**មាត្រា ២ :**

ម.ស.ម.ក. ជាស្ថាប័នជាតិដែលផ្តល់សេវាកម្មផ្នែកបោសសំអាតមីនដើម្បីមូលហេតុមនុស្សធម៌ និងបោសសំអាតមីនតាមកម្មវិធីអភិវឌ្ឍន៍ ។ ម.ស.ម.ក. មានសិទ្ធិផ្តល់សេវាកម្មដូចខាងលើតាមកិច្ចសន្យានៃកម្មវិធីអភិវឌ្ឍន៍ទាំងនោះ ។

## ជំពូកទី ២
## គោលដៅ និង សកម្មភាព

**មាត្រា ៣ :**

ម.ស.ម.ក. ត្រូវបំពេញភារកិច្ចដែលមានចែងក្នុងព្រះរាជក្រឹត្យនេះ ។ ភារកិច្ចទាំងឡាយណាដែលមានចែងនៅក្នុងមាត្រា ៤ មាត្រា ៥ នៃព្រះរាជក្រមលេខ នស/រកម/០៥៩៩/០៣ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការហាមប្រាមការប្រើប្រាស់គ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស ត្រូវផ្ទេរជូនទៅអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន ជាអ្នកអនុវត្ត និង ទទួលខុសត្រូវជំនួសវិញ ។ ការទទួលខុសត្រូវក្នុងការកំទេចគ្រាប់មីនដូចមានចែងខាងលើ គឺជាបន្ទុករបស់ ម.ស.ម.ក. ។

**មាត្រា ៤ :**

ម.ស.ម.ក. អាចចែករំលែកបច្ចេកទេស និង ការពិសោធន៍របស់ខ្លួន ទៅអោយប្រទេសទាំងឡាយណា ៗ

ដែលមានបញ្ហាមីន ។

**មាត្រា ៥ :**

ម.ស.ម.ក. ត្រូវអនុវត្តកម្មវិធីដូចតទៅ :

ក. ការយល់ដឹងអំពីគ្រោះថ្នាក់មីន

ខ. ពត៌មាន និង ការស្រាវជ្រាវអំពីចំការមីន

គ. ការបោសសំអាតមីន រួមបញ្ចូលទាំងការកំទេចគ្រឿងផ្ទុះចោល

ឃ. ការហ្វឹកហ្វឺនក្នុងសកម្មភាពមីន

ម.ស.ម.ក. ត្រូវចាត់វិធានការដើម្បីធានាសុវត្ថិភាពកំរិតខ្ពស់បំផុត អោយដល់បុគ្គលិកទាំងអស់របស់ខ្លួន ។

**មាត្រា ៦ :**

កម្មវិធីខាងលើ ត្រូវអនុវត្តក្នុងគោលបំណងសន្តិភាពតែប៉ុណ្ណោះ និង ត្រូវប្រព្រឹត្តទៅតាមលំដាប់អាទិភាពដូចតទៅ :

ក. បំរើគោលដៅមនុស្សធម៌ នៅតាមតំបន់ដែលមានអត្រានៃការរងគ្រោះដោយសារគ្រាប់មីនខ្ពស់

ខ. បំរើគោលដៅសេដ្ឋកិច្ច ដើម្បីជួយពង្រីកកសិកម្ម ជួយស្តារ ឬកសាងជាតិឡើងវិញ ឬដើម្បីអនុវត្តគំរោងអភិវឌ្ឍន៍ ។

## ជំពូកទី ៣
## ការគ្រប់គ្រងមជ្ឈមណ្ឌល

**មាត្រា ៧ :**

ម.ស.ម.ក. មានក្រុមប្រឹក្សាភិបាលមួយ និង អង្គភាពប្រតិបត្តិមួយ ។

## ជំពូកទី ៤
## ក្រុមប្រឹក្សាភិបាល

**មាត្រា ៨ :**

ក្រុមប្រឹក្សាភិបាល ម.ស.ម.ក. មានសមាជិក ៧ រូប ។ សមាជិកក្រុមប្រឹក្សាភិបាលត្រូវបានតែងតាំងឡើងដោយព្រះរាជក្រឹត្យតាមសំណើរបស់រាជរដ្ឋាភិបាល ។ល។

**មាត្រា ៩ :**

ក្រុមប្រឹក្សាភិបាលត្រូវមានប្រធានមួយ (១) រូប អនុប្រធានមួយ (១) រូប និង សមាជិកប្រាំ (៥) រូប ។ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានជាស្វ័យប្រវត្តិជាប្រធាននៃក្រុមប្រឹក្សាភិបាល ។ ក្នុងករណីដែលនាយករដ្ឋមន្ត្រីមិនអាចបំពេញមុខនាទីនេះដោយផ្ទាល់បាន នាយករដ្ឋមន្ត្រីអាចទូលស្នើព្រះមហាក្សត្រ សុំតែងតាំងឥស្សរជនមួយរូប ជាប្រធាននៃក្រុមប្រឹក្សាភិបាលផ្ទេរសិទ្ធ ។ ប្រធានក្រុមប្រឹក្សាភិបាលផ្ទេរសិទ្ធជាតំណាង ម.ស.ម.ក. ។

**មាត្រា ១០ :**

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវបានជ្រើសតាំងក្នុងចំណោមឥស្សរជន និង អ្នកឯកទេស ។ តំណាងជាប់ឆ្នោតម្នាក់នៃអង្គភាពប្រតិបត្តិរបស់ ម.ស.ម.ក. ត្រូវបានជ្រើសតាំងជាសមាជិកក្រុមប្រឹក្សាភិបាលដោយស្វ័យប្រវត្តិ ។ លើកលែងតែនាយករដ្ឋមន្ត្រី សមាជិកអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន មិនត្រូវបានជ្រើសតាំងជាសមាជិកនៃក្រុមប្រឹក្សាភិបាល ម.ស.ម.ក. ឡើយ ។

**មាត្រា ១១ :**

ក្នុងករណីប្រធានក្រុមប្រឹក្សាភិបាលអវត្តមាន ប្រធានក្រុមប្រឹក្សាភិបាលត្រូវប្រគល់សិទ្ធិអោយអនុប្រធានក្រុមប្រឹក្សាភិបាល ទទួលបន្ទុកជាប្រធានក្រុមប្រឹក្សាភិបាលផ្ទេរសិទ្ធស្ដីទី ។

**មាត្រា ១២ :**

ភ្នាក់ងារផ្ដល់ហិរញ្ញវត្ថុ អាចចូលរួមក្នុងសម័យប្រជុំក្រុមប្រឹក្សាភិបាលក្នុងឋានៈជាអ្នកសង្កេតការណ៍ ។ អ្នកសង្កេតការណ៍នៃភ្នាក់ងារផ្ដល់ហិរញ្ញវត្ថុនេះ មិនត្រូវមានចំនួនលើសពីពីរនាក់ទេ ។

**មាត្រា ១៣ :**

ប្រទេសផ្ដល់ជំនួយ អាចចូលរួមក្នុងសម័យប្រជុំក្រុមប្រឹក្សាភិបាលក្នុងឋានៈជាអ្នកសង្កេតការណ៍ ។

**មាត្រា ១៤ :**

ក្រុមប្រឹក្សាភិបាលមានអាណត្តិបីឆ្នាំ ហើយសមាជិកនៃក្រុមប្រឹក្សាភិបាលនេះ អាចត្រូវបានតែងតាំងជាថ្មីឡើងវិញបាន ។ល។

**មាត្រា ១៥ :**

ក្រុមប្រឹក្សាភិបាលត្រូវបើកកិច្ចប្រជុំសាមញ្ញមួយដងក្នុងមួយត្រីមាស ហើយនិងកិច្ចប្រជុំប្រចាំឆ្នាំមួយនៅដំណាច់ឆ្នាំសារពើពន្ធ ។ ប្រធាន ឬ សមាជិកភាគច្រើននៃក្រុមប្រឹក្សាភិបាលអាចកោះការប្រជុំជាវិសាមញ្ញបាន ។

**មាត្រា ១៦ :**

ការប្រជុំក្រុមប្រឹក្សាភិបាលនឹងយកជាការបាន លុះត្រាតែមានសមាជិកភាគច្រើនដាច់ខាតចូលរួម ។ ប្រសិនបើពុំមានសមាជិកភាគច្រើនដាច់ខាតមកចូលរួមប្រជុំទេ ប្រធានត្រូវកោះអញ្ជើញសមាជិកទាំងអស់ជាថ្មីម្តងទៀតមកប្រជុំ ហើយសមាជិកដែលមានវត្តមានតាមការអញ្ជើញនេះ នឹងយកជាគានការដើម្បីធ្វើការប្រជុំ ។ សមាជិកក្រុមប្រឹក្សាភិបាលត្រូវចូលរួមប្រជុំដោយផ្ទាល់ ។

**មាត្រា ១៧ :**

សមាជិកម្នាក់ៗត្រូវមានសិទ្ធិបញ្ចេញសម្លេងតែមួយគត់ ។ សេចក្តីសំរេចនឹងយកជាការបាន បើមានសម្លេងសមាជិកអង្គប្រជុំភាគច្រើនគាំទ្រ ។ នៅពេលដែលមានសមភាពរវាងសម្លេងគាំទ្រ និងសម្លេងមិនគាំទ្រ ប្រធានត្រូវធ្វើសេចក្តីសំរេចជាចុងក្រោយ ។

**មាត្រា ១៨ :**

ក្រុមប្រឹក្សាភិបាលត្រូវមានបទបញ្ជាផ្ទៃក្នុង ដើម្បីកំណត់របៀបរបបធ្វើការងាររបស់ក្រុមប្រឹក្សាភិបាល និង បែងចែកភារកិច្ចទទួលខុសត្រូវដល់សមាជិកនានា ។

**មាត្រា ១៩ :**

ក្រុមប្រឹក្សាភិបាលមានមុខងារដូចតទៅ :

ក. កំណត់យុទ្ធសាស្ត្រ និង នយោបាយដឹកនាំរបស់ ម.ស.ម.ក. ដោយផ្អែកលើមូលដ្ឋាននៃសំណើដែល ម.ស.ម.ក. បានស្នើឡើងដោយខ្លួនឯងទៅតាមជំនាញ និង បទពិសោធន៍របស់សមាជិកក្រុមប្រឹក្សាភិបាល ម.ស.ម.ក. ។

ខ. តាមដានសកម្មភាពរបស់ ម.ស.ម.ក. ហើយនិងផ្តល់ការណែនាំដើម្បីញ៉ាំងអោយកិច្ចប្រតិបត្តិការ ម.ស.ម.ក. ប្រព្រឹត្តទៅស្របនឹងគោលដៅ ហើយនិងសកម្មភាពរបស់មជ្ឈមណ្ឌល ដែលមានចែងក្នុងជំពូកទី ២ ។

គ. អនុម័តលើកម្មវិធី ផែនការការងារ ថវិកា គណនេយ្យ ហើយនិងរបាយការណ៍របស់ ម.ស.ម.ក. ។ ល។

ឃ. អនុម័តបទបញ្ជាផ្ទៃក្នុង និង ការរៀបចំរចនាសម្ព័ន្ធរបស់ ម.ស.ម.ក. ។

ង. អនុម័តសេចក្តីសំរេចលើបញ្ហាសំខាន់ៗទាំងឡាយឯទៀតដែលទាក់ទងនឹង ម.ស.ម.ក. ។

ច. ធ្វើសំណើទៅនាយករដ្ឋមន្ត្រី សុំតែងតាំងអគ្គនាយក ម.ស.ម.ក. និង ក្នុងករណីចាំបាច់ លើកអនុសាសន៍ជូននាយករដ្ឋមន្ត្រី សុំធ្វើការផ្លាស់ប្តូរអគ្គនាយក ម.ស.ម.ក ដោយផ្អែកតាមលទ្ធផលនៃការវាយតំលៃលើការអនុវត្តន៍ការងាររបស់អគ្គនាយក ។

**មាត្រា ២០:**

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល នឹងចូលជាធរមានប្រាំពីរថ្ងៃក្រោយដែលបានអនុម័តរួច លើកលែងតែការងារខ្លះដែលត្រូវចាត់ការជាចាំបាច់ និង បន្ទាន់ ។

**មាត្រា ២១ :**

តំណាងមកពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ ឥស្សរជនមួយរូប ដែលតែងតាំងឡើងដោយរាជរដ្ឋាភិបាល ត្រូវទទួលតំណែងជាហិរញ្ញិកនៃក្រុមប្រឹក្សាភិបាល និង មានមុខងារជាអាទិ៍ដូចតទៅ :

ក. ផ្តល់យោបល់លើការរៀបចំច្បាប់ទាំងឡាយខាងផ្នែកហិរញ្ញវត្ថុសំរាប់ដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និង អនុម័ត ។

ខ. សំរបសំរួលអោយមានការអនុវត្តន៍ហិរញ្ញកិច្ច សមស្របទៅតាមច្បាប់ជាធរមាន ។

គ. ពិនិត្យ និង ផ្តល់យោបល់លើសេចក្តីរាយការណ៍អំពីចំណូល-ចំណាយប្រចាំត្រីមាស របស់ ម.ស.ម.ក. ជូនក្រុមប្រឹក្សាភិបាល ។

ឃ. គ្រប់គ្រងរាល់ហិរញ្ញកិច្ច និង គណនេយ្យរបស់ក្រុមប្រឹក្សាភិបាល ប្រកបដោយប្រសិទ្ធភាព និង តម្លាភាពខ្ពស់ ។

## ជំពូកទី ៥
## អង្គភាពប្រតិបត្តិ

**មាត្រា ២២:**

អង្គភាពប្រតិបត្តិមាន អគ្គនាយកមួយរូប អគ្គនាយករងមួយរូប នាយកដ្ឋាន អង្គភាពបច្ចេកទេស និង អង្គភាពដោះមីន ។ ក្នុងករណីចាំបាច់ អគ្គនាយកអាចស្នើទៅក្រុមប្រឹក្សាភិបាល សុំបង្កើត ឬលុបចោល នូវនាយកដ្ឋាន និង/ឬ អង្គភាពដោះមីនបាន ។៚

**មាត្រា ២៣ :**

អង្គភាពប្រតិបត្តិ ត្រូវដឹកនាំដោយអគ្គនាយក ។ អគ្គនាយកត្រូវបានតែងតាំងឡើងដោយព្រះរាជក្រឹត្យ សំរាប់អាណត្តិបីឆ្នាំ តាមសេចក្តីស្នើសុំពីក្រុមប្រឹក្សាភិបាលទៅនាយករដ្ឋមន្ត្រី ។ អគ្គនាយក ជាអគ្គលេខាធិការនៃក្រុមប្រឹក្សាភិបាល ។ អគ្គនាយកអាចត្រូវតែងតាំងជាថ្មីឡើងវិញបាន ។

**មាត្រា ២៤ :**

អគ្គនាយកអាចស្នើការជ្រើសរើសអគ្គនាយករងមួយរូបទៅក្រុមប្រឹក្សាភិបាល ។ អគ្គនាយករងត្រូវតែងតាំងឡើងដោយអនុក្រឹត្យ ។

**មាត្រា ២៥ :**

អគ្គនាយក ម.ស.ម.ក. មានមុខងារជាអាទិ៍ដូចតទៅ :

ក. រៀបចំចាត់ចែង និង គ្រប់គ្រង ម.ស.ម.ក. ទៅតាមព្រះរាជក្រឹត្យនេះ ។

ខ. អនុវត្តគោលនយោបាយដឹកនាំរបស់ក្រុមប្រឹក្សាភិបាល ។

គ. ដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័តនូវកម្មវិធី ផែនការការងារ គំរោងថវិកា គណនេយ្យ ហើយនិងរបាយការណ៍ប្រចាំឆ្នាំរបស់ ម.ស.ម.ក. ។

ឃ.ដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន ភ្នាក់ងារផ្តល់ហិរញ្ញវត្ថុ និង ប្រទេសផ្តល់ជំនួយ នូវសេចក្តីរាយការណ៍ និង របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ ម.ស.ម.ក. ។

ង. ដឹកនាំកិច្ចប្រតិបត្តិការសកម្មភាពកំចាត់មីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ ស្របតាមផែនការការងារនិងកម្មវិធីដែលបានអនុម័តហើយរបស់ ម.ស.ម.ក. ប្រកបដោយប្រសិទ្ធិភាព និងតម្លាភាពខ្ពស់

ច. ចាត់ចែង និង ចេញបញ្ជាចំណាយនានា តាមគំរោងថវិកាដែលបានអនុម័តហើយ និង គ្រប់គ្រងលើរាល់ចំណូល-ចំណាយប្រចាំឆ្នាំរបស់ ម.ស.ម.ក. ។

ឆ. តែងតាំង ដឹកនាំបុគ្គលិក និង តំឡើងឋានន្តរសក្តិរបស់បុគ្គលិក នៃ ម.ស.ម.ក. ហើយនិងដាក់វិន័យទៅតាមបទបញ្ជា ដែលក្រុមប្រឹក្សាភិបាលបានសំរេចយល់ព្រមហើយ ដើម្បីលើកកំពស់ប្រសិទ្ធិភាព សមត្ថភាព និង ការស្មោគស្មឹក្នុងការធ្វើការងារអោយបានកំរិតខ្ពស់ ។

**មាត្រា ២៦ :**

ក្នុងករណីអគ្គនាយកអវត្តមាន អគ្គនាយកត្រូវផ្ទេរសិទ្ធិរបស់ខ្លួនទៅឱ្យអគ្គនាយករង ធ្វើជាអគ្គនាយកស្តីទី ។៚

## ជំពូកទី ៦
## ការចាត់ចែងហិរញ្ញវត្ថុ

**មាត្រា ២៧:**

ម.ស.ម.ក. ជាស្ថាប័នជាតិនៃព្រះរាជាណាចក្រកម្ពុជា ដែលពុំមានទិសដៅស្វែងរកចំណេញឡើយ ។ ម.ស.ម.ក. ត្រូវមានថវិការបស់ខ្លួនសំរាប់ការរៀបចំ ការប្រព្រឹត្តិទៅ និង សំរាប់កិច្ចប្រតិបត្តិការទាំងឡាយរបស់ខ្លួន ។

**មាត្រា ២៨:**

ម.ស.ម.ក. អាចសុំ អាចទទួល អាចទិញ ឬពុំនោះទេ អាចសុំពីស្ថាប័នរដ្ឋាភិបាល ឬ អន្តររដ្ឋាភិបាល ឬ ពីបុគ្គល ឬក៏ពីក្រុមហ៊ុន ឬក៏ពីស្ថាប័នឯទៀតៗ ដោយអំណោយក្តី ឬក៏ដោយមធ្យោបាយឯទៀតណាក៏ដោយក្តី នូវធនធានទាំងឡាយរាប់ទាំងប្រាក់កាស និង អំណោយដែលមានប្រយោជន៍ ឬដែលត្រូវការចាំបាច់ក្នុងការធ្វើអោយសំរេចគោលដៅរបស់ខ្លួន ។ ម.ស.ម.ក. អាចទិញចលនវត្ថុ ឬអចលនវត្ថុណាដែលចាំបាច់សំរាប់សកម្មភាពរបស់ខ្លួន ។

**មាត្រា ២៩:**

ម.ស.ម.ក. អាចតំរូវអោយរូបវន្តបុគ្គល ក្រុមហ៊ុន ឬស្ថាប័នផ្សេងៗ បង់ថ្លៃលើផលិតផល ឬសេវាដែលខ្លួនផ្តល់អោយ ។ ថ្លៃទាំងនេះមិនត្រូវអោយហួសលើសពីតម្លៃផលិតកម្មឡើយ ។

**មាត្រា ៣០:**

ម.ស.ម.ក. ត្រូវមានបែបបទហិរញ្ញវត្ថុរបស់ខ្លួន ហើយត្រូវដាក់របាយការណ៍ហិរញ្ញវត្ថុអោយបានទៀងទាត់ជូនទៅក្រុមប្រឹក្សាភិបាល ម.ស.ម.ក. ភ្នាក់ងារផ្តល់ហិរញ្ញវត្ថុ ប្រទេសផ្តល់ជំនួយ និង អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន ។

**មាត្រា ៣១:**

គណនេយ្យចំណាយ-ចំណូលរបស់ ម.ស.ម.ក. ត្រូវបើកចំហអោយមានការត្រួតពិនិត្យផែកនេរ ពីសំណាក់អង្គការឯករាជ្យណាមួយ តាមសំណើរបស់ភ្នាក់ងារផ្តល់ហិរញ្ញវត្ថុ ឬប្រទេសផ្តល់ជំនួយ ឬ អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន ។ សំណើសុំធ្វើការត្រួតពិនិត្យផែកនេរជាផ្លូវការខាងលើនេះ ត្រូវផ្ញើទៅក្រុមប្រឹក្សាភិបាល ម.ស.ម.ក. ។ល។

**មាត្រា ៣២ :**

ម.ស.ម.ក. ត្រូវបានរួចពីពន្ធគយលើទំនិញទាំងឡាយដែលខ្លួនទិញ ឬ ក៏ទទួលជាអំណោយ សំរាប់ការកកើត និង ការប្រព្រឹត្តទៅ ហើយនិងសកម្មភាពរបស់ខ្លួន ។

## ជំពូកទី ៧
## ការជាប់សំណង និង វិវាទ

**មាត្រា ៣៣ :**

បុគ្គលិក និងសមាជិកក្រុមប្រឹក្សាភិបាល ម.ស.ម.ក. នឹងមិនត្រូវជាប់សំណងផ្ទាល់ខ្លួនប្រភេទណាមួយ ដែលបណ្តាលមកពីការបំពេញមុខងារជាផ្លូវការរបស់ខ្លួនឡើយ ។

**មាត្រា ៣៤ :**

ម.ស.ម.ក. ត្រូវទទួលខុសត្រូវចំពោះករណីតវ៉ាអោយសងសំណងនេះ ទៅតាមច្បាប់ដែលមានជាធរមាន ។

**មាត្រា ៣៥ :**

ម.ស.ម.ក. ចេញមុខការពារ ឬប្តឹងតវ៉ាជំនួសបុគ្គលិក និង សមាជិកក្រុមប្រឹក្សាភិបាល ម.ស.ម.ក. ក្នុងករណីដែលមានវិវាទក្នុងការបំពេញមុខងារជាផ្លូវការរបស់ខ្លួន ។ ម.ស.ម.ក. មានភារកិច្ចចេញមុខការពារ តវ៉ា ឬ ដោះស្រាយការទាមទារ ឬ បណ្តឹងផ្សេងៗទៀត ដែលបណ្តាលមកពី សកម្មភាព ឬកិច្ចប្រតិបត្តិការ នៃ ម.ស.ម.ក. រាប់ទាំងថ្លៃចំណាយនៃរឿងវិវាទនោះផង ។ នីតិវិធីលំអិត ត្រូវកំណត់ដោយឡែកនៅក្នុងបទបញ្ជាផ្ទៃក្នុង ។

## ជំពូកទី ៨
## ផ្សេងៗ

**មាត្រា ៣៦ :**

ម.ស.ម.ក. ត្រូវស្ថិតនៅជាស្ថាប័នដែលអនុវត្តការងាររហូតដល់ទីបញ្ចប់នៃបេសកកម្មរបស់ខ្លួន និងរហូតដល់ការចាត់ចែងទ្រព្យសម្បត្តិ ការបំពេញកាតព្វកិច្ចនានា និង ការសងបំណុលរបស់ខ្លួន រួចរាល់ និង ចប់សព្វគ្រប់ ។ ការបញ្ចប់បេសកកម្មនៃ ម.ស.ម.ក. ហើយនិងការចាត់ចែងទ្រព្យសម្បត្តិ និងបំណុលរបស់ខ្លួន ត្រូវមានការទទួលយល់ព្រមពីរាជរដ្ឋាភិបាល ។៚

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

**មាត្រា ៣៧ :**

ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១៥ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា និង ព្រះរាជក្រឹត្យលេខ នស/រកត/០៦៩៩/១៣៨ ចុះថ្ងៃ ទី២១ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការសំរួលខ្លឹមសារនៃព្រះរាជក្រឹត្យស្តីពីការបង្កើតមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជានេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៨ :**

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣៩ :**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីពេលឡាយព្រះហស្តលេខាតទៅ ។ល។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែសីហា ឆ្នាំ ២០០១

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ: ៦៦៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០១

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**[illegible] តាន់**